# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ពណ៌នាអំពីសូចនាករសេដ្ឋកិច្ចនានានៃប្រទេសមានសេដ្ឋកិច្ចធំៗក្នុងពិភពលោក និងបណ្ដាប្រទេសនៅអាស៊ីខាងត្បូង និងអាស៊ីខាងកើត។

នៅត្រីមាសទី២ ឆ្នាំ២០១៤ កំណើនសេដ្ឋកិច្ចនៅប្រទេសមួយចំនួនក្នុងតំបន់អាស៊ី មានស្ថានភាពមិនសូវល្អទេ។ គិតក្នុងរយៈពេល ១២ខែ ផសស នៅប្រទេសសិង្ហបុរី កើន ២,៤% ធៀបនឹង ៣,៧% កាលពីឆ្នាំមុន រីឯកំណើនប្រចាំឆ្នាំនៅប្រទេសថៃ មានត្រឹម ០,៣% ដោយសារមានភាពតានតឹងផ្នែកនយោបាយ ក្នុងចំណោមអ្នកមានឋានៈខ្ពស់ដែលកាន់អំណាច។ ហុងកុង ក៏មានកំណើនសេដ្ឋកិច្ចយឺតដែរនៅត្រីមាសទី២ នេះ ត្រឹមតែ ១,៨% ធៀបនឹង ៣,៣% កាលពីឆ្នាំមុន។ ចលនាគាំទ្រលទ្ធិប្រជាធិបតេយ្យ ដែលមានការធ្វើបាតុកម្មបិទផ្លូវ និងរាំងស្ទះតំបន់ហិរញ្ញវត្ថុ បានជះឥទ្ធិពលលើសកម្មភាពសេដ្ឋកិច្ចនៅហុងកុង។ អ្នកវិភាគនានាបានក្រើនរំលឹកថា សេដ្ឋកិច្ចហុងកុងនឹងត្រូវខូចខាតច្រើនទៀត ប្រសិនបើការតវ៉ានេះនៅតែបន្តទៅមុខ។ ប្រទេសចិនបន្តមានដំណើរការសេដ្ឋកិច្ចល្អគួរសម ដោយមានកំណើន ៧,៥% ក្នុងរយៈពេលមួយឆ្នាំមកដល់ត្រីមាសទី២ ហើយបន្ទាប់មកគឺ ឥណ្ឌូនេស៊ី ដែលមានកំណើន ៦,៤%។

កំណើនសេដ្ឋកិច្ចនៅបណ្ដាប្រទេសឧស្សាហកម្ម ក៏ហាក់ដូចជាមិនសូវមានភាពជោគជ័យដែរ ដែលឆ្លុះបញ្ចាំងពីភាពមិនប្រាកដប្រជា និងការកែតម្រូវរចនាសម្ព័ន្ធដ៏ស្មុគស្មាញ ដែលត្រូវកែសម្រួលថែមទៀត។ សេដ្ឋកិច្ចនៅតំបន់ចាយប្រាក់អឺរ៉ូ កើន ០,៧% ក្នុងរយៈពេល ១២ខែកន្លងទៅ រីឯសេដ្ឋកិច្ចជប៉ុន រួមចុះ ០,១%។ ធនាគារជាតិជប៉ុន បានប្រកាសពីផែនការសម្រួលបរិមាណរូបិយវត្ថុមួយ ដើម្បីផ្គត់ផ្គង់សាច់ប្រាក់ ៨០លានលានយេន (៧១២ពាន់លានដុល្លារ) ក្នុងមួយឆ្នាំ ដែលជាផ្នែកមួយនៃគំនិតផ្ដួចផ្ដើម "ព្រួញបី" តាមទ្រឹស្ដី Abenomic សំដៅជាស់សកម្មភាពសេដ្ឋកិច្ច និងចៀសផុតពីបរិត្តផរណា។ គេនៅរង់ចាំមើលថា តើផែនការដ៏ក្លាហាននេះ នឹងផ្ដល់លទ្ធផលដូចការរំពឹងទុក ឬយ៉ាងណា។ សហរដ្ឋអាមេរិកសម្រេចបានជោគជ័យច្រើនជាង ប្រទេសមានសេដ្ឋកិច្ចជឿនលឿនឯទៀតៗ ដោយទទួលបានកំណើនប្រចាំឆ្នាំ ២,៦% ធៀបនឹង ១,៤% កាលពីត្រីមាសមុន។ ការិយាល័យស្ថិតិពលកម្មរបស់សហរដ្ឋអាមេរិក បានឲ្យដឹងថា នៅខែកញ្ញា ២០១៤ មានការបង្កើតការងារ ២៤៨.០០០កន្លែងថែមទៀត ដែលធ្វើឲ្យអត្រាគ្មានការងារធ្វើស្ថិតនៅត្រឹមកម្រិត ៥,៩% ដោយបានថយចុះ ១,៣ ឯកត្តាភាគរយ ធៀបនឹងឆ្នាំមុន។ គោលនយោបាយបង្កើនរូបិយវត្ថុ និងបង្កើនហិរញ្ញវត្ថុ ត្រូវបានយកមកប្រើដើម្បីកែលំអស្ថានភាពសេដ្ឋកិច្ច ដែលកំពុងធ្លាក់ចុះធ្ងន់ធ្ងរបំផុត គិតតាំងពីពេលមានមហាវិបត្តិសេដ្ឋកិច្ច (Great Depression) រហូតមកទល់សព្វថ្ងៃ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់

នៅត្រីមាសទី២ ឆ្នាំ២០១៤ អត្រាអតិផរណានៅគ្រប់ប្រទេសមានកម្រិតទាប និងអាចគ្រប់គ្រងបាន។ ថ្លៃទំនិញនៅកម្ពុជាកើន ៤,៩% ធៀបមួយឆ្នាំមុន។ អតិផរណានៅវៀតណាម មានកម្រិត ៤,៧%។ អត្រាអតិផរណានេះ ឡើងខ្ពស់ដល់ ២៣,៣% នៅឆ្នាំ២០០៨ ក្នុងពេលដែលវៀតណាមអនុវត្តគោលនយោបាយកញ្ចប់ជំរុញសកម្មភាពសេដ្ឋកិច្ច ដើម្បីទប់ទល់នឹងឥទ្ធិពល នៃវិបត្តិហិរញ្ញវត្ថុសកល។ អតិផរណានៅតំបន់ចាយប្រាក់អឺរ៉ូ មានកម្រិតទាបត្រឹម ០,៦%។ ជប៉ុនបានងើបផុតពីបរិត្តផរណាដោយមានអត្រាអតិផរណា ៣,៦%។ ធនាគារជាតិជប៉ុន បានអនុវត្តគោលនយោបាយសម្រួលបរិមាណសាច់ប្រាក់ ដើម្បីរក្សាអត្រាអតិផរណាក្នុងកម្រិត ២% ក្នុងមួយឆ្នាំ។ អតិផរណានៅសហរដ្ឋអាមេរិក មានអត្រា ២,១% ដែលជាកម្រិតមួយស្របតាមការកំណត់នៅក្នុងគោលនយោបាយគ្រប់គ្រងអតិផរណា របស់ក្រុមប្រឹក្សាធនាគារជាតិសហរដ្ឋអាមេរិក (Federal Reserve Board)។

នៅត្រីមាសទី២ ប្រាក់រៀល ឡើងថ្លៃ ០,១% ទល់នឹងប្រាក់ដុល្លារ ធៀបនឹងឆ្នាំមុន ហើយប្រាក់វ៉ុនកូរ៉េខាងត្បូង ឡើងថ្លៃ ៨,៤%។ ប្រាក់យេនជប៉ុន ធ្លាក់ថ្លៃ ៣,៣% ទល់នឹងប្រាក់ដុល្លារ ដែលធ្វើឲ្យផលិតផលជប៉ុន មានឧត្តមភាពប្រកួតប្រជែងនៅលើទីផ្សារពិភពលោក។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី២ ឆ្នាំ២០១៤ ពោត ធ្លាក់ថ្លៃ ២៦,៣% ធៀបមួយឆ្នាំមុន មកត្រឹម ១២៤,៧ដុល្លារ/តោន, កៅស៊ូ ធ្លាក់ថ្លៃ ២៨,៨% មកត្រឹម ១៧៧៨ដុល្លារ/តោន ហើយ អង្ករ ធ្លាក់ថ្លៃ ២៧,៨% មកត្រឹម ៤១១,៧ដុល្លារ/តោន។ ថ្លៃកៅស៊ូ មាននិន្នាការធ្លាក់ចុះ គិតចាប់ពីត្រីមាសទី១ ឆ្នាំ២០១៣ មក។ ប្រេងឆា ឡើងថ្លៃ ៤,៤% ដល់ ៨៨៧,៣ដុល្លារ/តោន ហើយ ប្រេងឆៅ ឡើងថ្លៃ ៥,០% ដល់ ១០៥,៩ដុល្លារ/ធុង។ គិតចាប់ពីឆ្នាំមុនមក ថ្លៃទំនិញកសិកម្មមាននិន្នាការធ្លាក់ចុះ។

---

អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

តារាង ១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៤ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.2 | 6.8 | 0.1 | 6.0 | 6.1 | 6.2 | - | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 6.3 | 6.1 | 4.2 | 6.2 | 6.5 | 6.3 | 6.0 | 5.8 | 5.6 | 5.7 | 5.2 | 5.1 |
| ម៉ាឡេស៊ី | 6.3 | 4.6 | -2.4 | 9.0 | 4.9 | 5.4 | 4.1 | 4.3 | 5.0 | 5.1 | 6.2 | 6.4 |
| សិង្ហបុរី | 7.7 | 1.1 | -4.5 | 14.7 | 4.7 | 1.3 | 0.2 | 3.7 | 5.8 | 5.5 | 5.1 | 2.4 |
| ថៃ | 4.9 | 2.6 | 3.3 | 7.9 | 0.0 | 6.8 | 5.4 | 2.6 | 2.6 | 0.4 | 3.1 | 0.3 |
| វៀតណាម | 8.5 | 6.2 | 4.7 | 6.7 | 6.1 | 5.0 | - | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 11.9 | 9.0 | 8.2 | 10.4 | 9.3 | 7.8 | 7.7 | 7.5 | 7.8 | 7.7 | 7.1 | 7.5 |
| ហុងកុង | 6.4 | 2.4 | -3.2 | 6.9 | 4.9 | 2.9 | 2.8 | 3.3 | 2.9 | 3.0 | 2.5 | 1.8 |
| កូរ៉េខាងត្បូង | 4.9 | 2.2 | -1.0 | 6.1 | 3.6 | 2.1 | 1.5 | 2.3 | 3.3 | 4.0 | 4.1 | 3.5 |
| តៃវ៉ាន់ | 5.2 | 0.1 | -3.6 | 11.1 | 4.2 | 1.2 | 1.7 | 2.3 | 1.7 | 2.9 | 3.1 | 3.7 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.9 | 0.9 | -3.8 | 1.6 | 1.6 | -0.5 | 1.1 | -0.7 | -0.4 | 0.5 | 0.9 | 0.7 |
| ជប៉ុន | 2.0 | -0.7 | -5.4 | 4.1 | -0.8 | 1.7 | 0.4 | 0.9 | 2.7 | 2.6 | 3.1 | -0.1 |
| សហរដ្ឋអាមេរិក | 2.2 | 1.1 | -2.5 | 2.7 | 1.8 | 2.1 | 1.8 | 1.4 | 1.6 | 2.5 | 2.3 | 2.6 |

Sources: International Monetary Fund, Economist and countries' statistic offices

តារាង ២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៤ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.5 | 19.7 | -0.5 | 4.1 | 5.5 | 3.0 | 1.5 | 2.2 | 3.8 | 4.3 | 4.5 | 4.9 |
| ឥណ្ឌូណេស៊ី | 6.4 | 10.1 | 4.7 | 5.1 | 5.4 | 4.3 | 5.3 | 5.7 | 8.6 | 8.4 | 7.7 | 7.1 |
| ម៉ាឡេស៊ី | 2.0 | 5.3 | 0.4 | 1.7 | 3.2 | 1.7 | 1.4 | 1.8 | 2.2 | 3.0 | 3.5 | 3.3 |
| សិង្ហបុរី | 2.1 | 6.5 | 0.5 | 2.9 | 5.2 | 4.6 | 3.6 | 1.6 | 1.8 | 2.0 | 1.0 | 2.3 |
| ថៃ | 2.2 | 5.5 | -0.9 | 3.1 | 3.8 | 3.0 | 3.1 | 2.3 | 1.7 | 1.7 | 2.0 | 2.5 |
| វៀតណាម | 8.3 | 23.3 | 7.3 | 9.0 | 18.6 | 9.3 | 6.9 | 6.6 | 7.0 | 5.9 | 4.8 | 4.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 4.8 | 5.9 | -0.8 | 3.2 | 5.4 | 2.7 | 2.4 | 2.4 | 2.8 | 2.9 | 2.1 | 2.2 |
| ហុងកុង | 2.0 | 4.3 | -0.3 | 2.4 | 5.3 | 4.1 | 2.2 | 4.0 | 5.3 | 4.3 | 4.1 | 3.6 |
| កូរ៉េខាងត្បូង | 2.5 | 4.6 | 2.8 | 3.0 | 4.4 | 2.1 | 1.4 | 1.1 | 1.2 | 0.9 | 1.1 | 1.6 |
| តៃវ៉ាន់ | 1.8 | 3.2 | -1.1 | 1.0 | 1.4 | 1.9 | 1.8 | 0.8 | 0.0 | 0.5 | 1.1 | 1.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 3.3 | 0.4 | 1.6 | 2.7 | 2.5 | 1.8 | 1.5 | 1.3 | 0.6 | 0.6 | 0.6 |
| ជប៉ុន | 0.1 | 1.4 | -1.3 | -0.7 | 0.1 | -0.03 | -0.3 | -0.3 | 0.9 | 1.4 | 1.5 | 3.6 |
| សហរដ្ឋអាមេរិក | 2.9 | 3.8 | -0.4 | 1.7 | 3.2 | 2.1 | 1.7 | 1.4 | 1.6 | 1.2 | 1.4 | 2.1 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង ៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4062.7 | 4054.2 | 4140.5 | 4187.1 | 4063.6 | 4037.8 | 3995.0 | 4032.9 | 4062.0 | 4018.9 | 3993.8 | 4026.9 |
| ឥណ្ឌូណេស៊ី (រូពីយ៉ា) | 9419.0 | 9699.0 | 10,413.8 | 9089.9 | 8764.4 | 9363.0 | 9681.9 | 9783.6 | 10,666.0 | 11,545.1 | 11,765.8 | 11,615.3 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.3 | 3.5 | 3.2 | 1.5 | 3.1 | 3.1 | 3.0 | 3.2 | 3.2 | 3.3 | 3.2 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.5 | 1.4 | 1.5 | 1.4 | 1.3 | 1.2 | 1.2 | 1.2 | 1.3 | 1.3 | 1.3 | 1.3 |
| ថៃ (បាត) | 32.2 | 33.4 | 34.3 | 31.7 | 30.5 | 31.1 | 29.8 | 29.9 | 31.4 | 31.7 | 32.6 | 32.4 |
| វៀតណាម (ដុង) | 16,030.0 | 16,382.0 | 17,725.2 | 19,200.8 | 20,574.3 | 20,856.9 | 20,829.6 | 20,828.0 | 20,908.7 | 21,036.0 | 21,036.0 | 21,036.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 8.0 | 6.9 | 6.8 | 6.8 | 3.3 | 6.3 | 6.2 | 6.2 | 6.1 | 6.1 | 6.1 | 6.2 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 929.0 | 1137.2 | 1277.8 | 1156.3 | 1108.6 | 1126.6 | 1085.9 | 1123.4 | 1108.8 | 1062.0 | 1069.7 | 1028.9 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.9 | 31.5 | 33.0 | 31.3 | 29.4 | 29.6 | 29.5 | 29.9 | 29.9 | 29.6 | 30.3 | 30.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.7 | 0.8 | 0.7 | 0.8 | 0.7 | 0.8 | 0.8 | 0.8 | 0.8 | 0.7 | 0.7 | 0.7 |
| ជប៉ុន (យ៉េន) | 117.8 | 102.5 | 93.6 | 87.8 | 79.9 | 79.8 | 92.3 | 98.8 | 98.9 | 100.5 | 102.8 | 102.1 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង ៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៧-២០១៤ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ពោត (US No. 2) - USA (USD/តោន) | 149.1 | 218.2 | 167.3 | 167.3 | 291.4 | 296.5 | 305.2 | 291.4 | 246.2 | 199.3 | 209.6 | 214.7 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 707.7 | 912.2 | 686.8 | 834.7 | 1125.4 | 999.3 | 852.7 | 850.3 | 827.3 | 897.3 | 911.3 | 887.3 |
| កៅស៊ូ SMR 5 (USD/តោន) | 2202.3 | 2586.3 | 1884.8 | 3152.2 | 4630.6 | 3200.7 | 3029.5 | 2497.2 | 2394.6 | 2380.0 | 2034.7 | 1777.6 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 305.4 | 615.3 | 524.5 | 456.2 | 558.5 | 594.8 | 607.0 | 570.0 | 502.3 | 455.7 | 450.7 | 411.7 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 294.6 | 460.4 | 414.0 | 375.4 | 507.9 | 566.1 | 558.4 | 569.8 | 545.1 | 514.9 | 533.0 | 565.7 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 69.3 | 95.4 | 60.5 | 71.6 | 106.2 | 109.5 | 109.5 | 100.9 | 106.9 | 106.4 | 104.7 | 105.9 |
| សាំង - US Gulf Coast (សេន/លីត្រ) | 53.6 | 62.2 | 42.9 | 49.8 | 71.9 | 74.6 | 74.8 | 71.2 | 73.3 | 65.7 | 70.1 | 74.1 |
| ម៉ាស៊ូត (ស្តាន់ដ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 55.5 | 51.6 | 75.7 | 83.8 | 77.8 | 80.7 | 80.3 | 81.5 | 75.6 | 79.6 | 77.5 | 77.1 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចចម្បងៗ

តាមការគន់គូរ សេដ្ឋកិច្ចកម្ពុជានឹងរក្សាកំណើនខ្លាំងក្នុងអត្រា ៧,0% សម្រាប់ឆ្នាំ២០១៤។ ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ក៏បានធ្វើការប៉ាន់ស្មានប្រហាក់ប្រហែលនេះដែរ។ ទោះយ៉ាងណាក្តី ត្រូវធ្វើការកែសម្រួលលើការតម្រូវរចនាសម្ព័ន្ធដ៏ស្មុគស្មាញមួយចំនួន ជាពិសេស ខាងផ្នែកអប់រំ និងការផ្សារភ្ជាប់ជំនាញទៅនឹងតម្រូវការទីផ្សារ។

នៅត្រីមាសទី២ ឆ្នាំ២០១៤ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ មានស្ថានភាពមិនល្អទេ ដោយគម្រោងអនុម័តចេញបានធ្លាក់ចុះ ៨៥,៥% ធៀបឆ្នាំមុន មកត្រឹម ៣០២,២លានដុល្លារ។ វិនិយោគក្នុងវិស័យឧស្សាហកម្ម ធ្លាក់ចុះ ៨៧,៦% មកត្រឹម ២៣៩,៣លានដុល្លារ។ វិនិយោគខាងផ្នែកកាត់ដេរនៅតែខ្លាំងក្លា ដោយរួមចំណែក ៧២% ក្នុងវិនិយោគទុនសរុបខាងវិស័យឧស្សាហកម្ម។ វិស័យសេវាកម្មបន្តមានដំណើរការល្អដោយវិនិយោគកើនឡើង ៧,៩% ធៀបឆ្នាំមុន។ វិនិយោគក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងសណ្ឋាគារ ធ្លាក់ចុះ ៨៥,៥% មកត្រឹម ១៥,៤លានដុល្លារ។

ចំនួនភ្ញៀវបរទេសមកដល់កម្ពុជា កើនបានត្រឹម ១,៤% ធៀបនឹងឆ្នាំមុន ដល់ ៩៣៣.000នាក់។ ទោះយ៉ាងនេះក្តី ក្រសួងទេសចរណ៍ មានសុទិដ្ឋិនិយមថា កម្ពុជានឹងទទួលបានភ្ញៀវទេសចរប្រមាណ ៤លាននាក់ ក្នុងឆ្នាំ២០១៤ ដោយទទួលបាន ២,២លាននាក់រួចជាស្រេច នៅក្នុងឆមាសទី១ ។ ចំនួនភ្ញៀវមកដល់តាមផ្លូវអាកាស កើន ១០,១% ធៀបនឹងឆ្នាំមុន ប៉ុន្តែភ្ញៀវមកដល់តាមផ្លូវគោក ឬផ្លូវទឹក ធ្លាក់ចុះ ៥,២%។

នៅត្រីមាសទី២ ការនាំចេញ កើន ១៤,៨% ធៀបឆ្នាំមុនក្នុងនេះ ការនាំចេញសម្លៀកបំពាក់ កើន ៩,៥% និងរួមចំណែក ៧៤,២% ក្នុងតម្លៃនាំចេញសរុប។ ទីផ្សារចម្បងៗរួមមាន សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិកដែលមានចំណែក ៤០,៥% និង ៣២,៨% រៀងគ្នា ក្នុងតម្លៃនៃការនាំចេញសម្លៀកបំពាក់។ ទោះយ៉ាងនេះក្តី ការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក បានធ្លាក់ចុះ ៤,៧% បើធៀបនឹងឆ្នាំមុន។ មានការលើកមតិឲ្យស្វែងរកទីផ្សារនាំចេញថែមទៀត ដើម្បីទប់ទល់នឹងការប៉ះទង្គិចមិនអាចរំពឹងឃើញផ្សេងៗ នៅក្នុងប្រទេសជាគោលដៅនាំចេញចម្បងៗ។ ការនាំចេញផលិតផលកសិកម្ម កើន ២២,0% ធៀបឆ្នាំមុន។ ការនាំចេញកៅស៊ូ កើន ៣,៤% ទោះបីជាថ្លៃកៅស៊ូបន្តធ្លាក់ចុះក្តី។ នៅត្រីមាសទី២នេះដែរ ការនាំចូលសរុប កើន ១០,៨% ធៀបឆ្នាំមុន ដល់ ២,៤ពាន់លានដុល្លារ។ ការនាំចូលសាំង កើន ៧,៨%, ការនាំចូលម៉ាស៊ូត កើន ៣,៧% ហើយការនាំចូលសម្ភារសំណង់ កើន ៦៤%។ ឱនភាពពាណិជ្ជកម្ម ថយចុះ ៤៣,៤% ធៀបឆ្នាំមុន មកត្រឹម ៣៣៤,៧លានដុល្លារ។

## ហិរញ្ញវត្ថុសាធារណៈ

តាមការផ្តល់មតិមួយរបស់ដៃគូអភិវឌ្ឍន៍នានា (ឧ. ធនាគារពិភពលោក) គឺរដ្ឋាភិបាល ត្រូវអនុវត្តកំណែទម្រង់ឲ្យបានមធ្យ័តនិងពេញលេញក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពង្រឹងការប្រមូលចំណូល និងកាត់បន្ថយចំណាយខ្ជះខ្ជាយ។ រដ្ឋាភិបាលបានបញ្ជាក់ជាថ្មី ពីការប្តេជ្ញាចិត្តរបស់ខ្លួន និងបានដាក់អនុវត្តកំណែទម្រង់ជាជំហានៗ លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ នៅត្រីមាសទី១ ឆ្នាំ២០១៤ ចំណូលសរុបរបស់រដ្ឋាភិបាល កើន ២២,0% ធៀបឆ្នាំមុន ដល់ ២២២០,៥ពាន់លានរៀល។ ចំណូលពន្ធ កើន ២៦,១% រីឯចំណូលមិនមែនពន្ធ ធ្លាក់ចុះ ២៦,៤%។ នៅត្រីមាសទី១ នេះដែរ ចំណាយសរុបធ្លាក់ចុះ ២២,៣% មកត្រឹម ១៦៤២,៤ពាន់លានរៀល ប៉ុន្តែចំណាយចរន្ត កើន ៤២,៥%។ ចំណាយលើបៀវត្សរ៍ កើន ៧0,២% ធៀបឆ្នាំមុន រីឯចំណាយលើឧបត្ថម្ភធន និងជំនួយសង្គមធ្លាក់ចុះ ១៥,៤%។ កំណើនបៀវត្សរ៍មន្ត្រីរាជការ (ឧ. គ្រូបង្រៀន) ជាកត្តាបង្កកំណើនចំណាយលើបៀវត្សរ៍។

## អតិផរណា និង ការវិវត្តរូបិយវត្ថុ

អតិផរណានៅត្រីមាសទី២ កើនដល់ ៤,៨%។ ថ្លៃអាហារនិងភេសជ្ជៈគ្មានជាតិស្រា កើន ៥,៣%។ អតិផរណាមាននិន្នាការកើនឡើង ចាប់តាំងពីឆ្នាំ២០១៣ មក ដែលនាំឲ្យចំណាយលើជីវភាពកើនឡើងដែរ។

នៅត្រីមាសទី២ ឆ្នាំ២០១៤ ប្រាក់រៀលឡើងថ្លៃ 0,២% ទល់នឹងប្រាក់ដុល្លារ និង ៨,១% ទល់នឹងប្រាក់បាតថៃ។ មាសធ្លាក់ថ្លៃ ១០,១% ធៀបឆ្នាំមុន មកត្រឹម ១៥៥,៩ដុល្លារ/ជី។ សាំងធ្លាក់ថ្លៃ ១,៤% មកត្រឹម ៥២00រៀល/លីត្រ រីឯម៉ាស៊ូតឡើងថ្លៃ 0,៣% ដល់ ៥00៦,៧រៀល/លីត្រ។ ថ្លៃម៉ាស៊ូតនិងសាំងក្នុងស្រុក ហាក់ដូចគ្មានប្រែប្រួលទេ ទោះបីជាថ្លៃប្រេងឆៅនៅលើទីផ្សារពិភពលោកមាននិន្នាការធ្លាក់ចុះក្តី។

នៅត្រីមាសទី២ ដដែលនេះ សាច់ប្រាក់ងាយស្រួលសរុបកើន ២០,៨% ធៀបឆ្នាំមុន។ ទ្រព្យសកម្មបរទេសសុទ្ធ កើន ២០,៥% ហើយទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ២១,៦%។ រូបិយវត្ថុទូទៅ កើន ១៤,១% ធៀបឆ្នាំមុន ហើយរូបិយវត្ថុផ្សេងៗកើន ២២,0%។ កំណើនសាច់ប្រាក់ងាយស្រួលសរុបជាដំណឹងល្អ សម្រាប់ប្រទេសមានសេដ្ឋកិច្ចកំពុងរីកចម្រើន។ ទោះយ៉ាងនេះក្តី ធនាគារជាតិត្រូវពិនិត្យឲ្យដិតដល់ថា ឥណទានផ្តោតចំវិស័យមានផលិតភាពនានា។ លើសពីនេះ ត្រូវពិនិត្យលើកំណើនរូបិយវត្ថុទូទៅ និងរូបិយវត្ថុផ្សេងៗ ព្រមទាំងអត្រាអតិផរណាផងដែរ។

## ស្ថានភាពក្រីក្រ

នៅខែសីហា ២០១៤ ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ អ្នកលីសែង អ្នករើសអេតចាយ និងអ្នករត់ម៉ូតូឌុប បានធ្លាក់ចុះ បើធៀបឆ្នាំមុន។ គិតពីខែឧសភា តមក ចំណូលរបស់កម្មកររោងចក្រកាត់ដេរ បានធ្លាក់ចុះ រីឯចំណូលរបស់អ្នកលីសែង កើនឡើង។

---

អត្ថបទនេះរៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

ចំណូលប្រចាំថ្ងៃពិតរបស់អ្នកស៊ីឈ្នួលធ្វើស្រែ កើន ៤៥% ធៀបនឹងអង្កេតលើកមុន ដល់ ៨៤៩៥រៀល។ កត្តាចម្បង គឺចំនួនកម្មករតិចជាងមុន ដែលធ្វើឲ្យប្រាក់កម្រៃកើនឡើងនៅខេត្តកំពង់ស្ពឺ និង កណ្ដាល។ ប្រហែល ៦៧% នៃកម្មករទាំងនេះ ក៏ត្រូវធ្វើការលើដីកសិកម្មរបស់ខ្លួនឯងដែរ ដែលមានទំហំប្រមាណ ០,១ ទៅ ១,៥ហិកតា ហើយអាចផ្ដល់នូវប្រាក់បន្ថែមពីលើចំណូលបានពីការលក់កម្លាំងពលកម្ម។ កសិករដែលគ្មានដីធ្លីត្រូវទ្រទ្រង់ជីវភាពគ្រួសារ ដោយប្រើប្រាស់ធនធានទ្រព្យរួមការចិញ្ចឹមមាន់ទា និងការខ្ចីបុល។ អ្នកស៊ីឈ្នួលធ្វើស្រែ ចំណាយ ២៩% នៃប្រាក់រកបាន ទៅលើម្ហូបអាហារ ដោយត្រូវធ្វើការជាមធ្យម ២៤ថ្ងៃ ក្នុងមួយខែ។

ចំណូលរបស់អ្នកលក់បន្លែ កើន ១៣% ដល់ ១៥.៣៧២ រៀល/ថ្ងៃ។ ក្នុងក្រុមនេះ មាន ៥៣% មកពីខេត្តកណ្ដាល ដូច្នេះអាចធ្វើដំណើរទៅមករៀងរាល់ថ្ងៃ។ សមាជិកក្រុមនេះ ៥៤% ស្នាក់នៅផ្ទះជួល ឬនៅជាមួយសាច់ញាតិ ឬនៅតាមវត្ត។ ពួកគេចាយវាយអស់ត្រឹមតែ ៣៩% នៃប្រាក់រកបានប៉ុណ្ណោះ ប៉ុន្តែប្រាក់ចំណូលតិចតួចនេះ នៅតែមិនគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ។ អ្នកលក់បន្លែ ៧៥% ប្រាប់ថា ចង់ពង្រីកអាជីវកម្មខ្លួន ដើម្បីរកចំណូលបន្ថែម ប៉ុន្តែមិនមានលទ្ធភាពធ្វើ។

ចំណូលរបស់អ្នកបម្រើតាមភោជនីយដ្ឋាន កើន ១៣% ធៀបនឹងខែឧសភា ដល់ ៧៥៦៥រៀល/ថ្ងៃ។ កម្មករគ្រប់គ្នាក្នុងអង្កេតនេះ ជាអ្នកមកពីខេត្ត ក្នុងនោះមាន ៣៨% មកពីព្រៃវែង។ ក្រៅពីប្រាក់កម្រៃ ពួកគេទទួលបានអាហារ និងកន្លែងស្នាក់នៅ ប៉ុន្តែពិបាកនឹងសន្សំប្រាក់បាន ពីព្រោះត្រូវទ្រទ្រង់គ្រួសារនៅឯខេត្ត។

ចំណូលពិតរបស់អ្នករើសអេតចាយ ធ្លាក់ចុះ ៩,៥% ធៀបនឹងអង្កេតលើកមុន មកត្រឹម ៨៣៣៧រៀល/ថ្ងៃ។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ទាំង ៤០នាក់ មាន ៥៥% មកពីខេត្តព្រៃវែង និងខ្លះទៀតមកពីខេត្តកណ្ដាល។ ក្នុងចំណោមពួកគេ មាន ៣៥នាក់ មករាជធានីភ្នំពេញជាមួយក្រុមគ្រួសារទាំងមូល។ អ្នករើសអេតចាយទាំងអស់ ត្រូវជួលកន្លែងស្នាក់នៅ និងតែងស្នាក់នៅជាមួយមនុស្ស ៤នាក់ផ្សេងទៀតជាមធ្យម។ ពួកគេមិនមានការងារអ្វីផ្សេងទេ ហើយប្រាក់រកបានអាចដោះស្រាយតម្រូវការចាយវាយបានតែមួយភាគ ដូច្នេះមាន ៧៥% បានខ្ចីប្រាក់គេ។

អ្នកធាក់ស៊ីក្លូរហូតដល់ ៩៥% បានឆ្លើយសម្ភាសន៍ប្រាប់ថា គាត់មកពីខេត្ត ភាគច្រើន ខេត្តព្រៃវែង និងកំពង់ស្ពឺ (២៣% ដូចគ្នា)។ ក្រុមនេះមានប្រាក់ចំណូល ៩៨៦៧រៀល/នាក់/ថ្ងៃ ដែលទាបជាងកាលពីខែឧសភា ដល់ ៨,៣% និងមាន ៩៧,៥% ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ។ ប្រាក់កម្រៃរកបានមិនគ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់លើរាល់ចំណាយក្នុងគ្រួសារនោះទេ ដូច្នេះមាន ៦៥% ត្រូវចិញ្ចឹមសត្វ ដូចជាមាន់ទា ដើម្បីរកចំណូលបន្ថែម។ រហូតដល់ ៨៨% នៃអ្នកធាក់ស៊ីក្លូដែលបានឆ្លើយសម្ភាសន៍ ធ្វើដំណើរមករាជធានីភ្នំពេញតែម្នាក់ឯង ហើយត្រូវជួលកន្លែងស្នាក់នៅជាមធ្យមជាមួយមនុស្ស ៣ ឬ ៤នាក់ផ្សេងទៀត។ គាត់ចាយវាយអស់ ៥៦% នៃចំណូលរកបាន ហើយចំណាយលើម្ហូបអាហារ មានចំណែក ៩៤% នៃចំណាយសរុប។

ចំណូលរបស់អ្នករត់ម៉ូតូឌុប ធ្លាក់ចុះ ៥,៦% ធៀបនឹងខែឧសភា មកត្រឹម ១២.៦៥៦រៀល/ថ្ងៃ។ រហូតដល់ ៩០% នៃអ្នកឆ្លើយសម្ភាសន៍ បានប្រាប់ថា ចំនួនអ្នករត់ម៉ូតូឌុបកើនឡើង រីឯចំនួនអតិថិជននៅថេរដដែល។ អ្នករត់ម៉ូតូឌុបឆ្លើយសម្ភាសន៍ ២០% អាចពឹងផ្អែកលើប្រាក់ចំណូលខ្លួនដើម្បីទ្រទ្រង់គ្រួសារ រីឯ ៨០% ទៀត ត្រូវពឹងផ្អែកលើប្រភពចំណូលដទៃទៀត ជាពិសេសការចិញ្ចឹមមាន់ទានៅផ្ទះ។ ជាមធ្យម ពួកគាត់ចាយវាយអស់ ៤១% នៃប្រាក់ចំណូលរបស់គាត់ ហើយ ចំណាយលើម្ហូបអាហារ មានចំណែក ៩៤% នៃចំណាយសរុប។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នាប្រាប់ថា មិនមានសល់ប្រាក់សម្រាប់សន្សំទុកនោះទេ។

ក្នុងចំណោមកម្មកររោងចក្រកាត់ដេរឆ្លើយសម្ភាសន៍ គ្មានអ្នកណាបានបញ្ចប់ថ្នាក់បឋមសិក្សាឡើយ។ ពួកគេទទួលបានកម្រៃ ១១.៣៨៨រៀល/ថ្ងៃ ឬធ្លាក់ចុះ ០,២% ធៀបនឹងអង្កេតលើកមុន។ មានតែ ១១% នៃកម្មករទាំងនោះប៉ុណ្ណោះ ដែលទទួលបានការបណ្ដុះបណ្ដាលជាឯកជន មុនពេលចូលធ្វើការ។ ជាមធ្យមពួកគេបម្រើការក្នុងរោងចក្រកាត់ដេរបច្ចុប្បន្ន បានជាងពីរឆ្នាំមកហើយ រីឯការងារជាក់ស្ដែងគឺ ដេរ និងមុខងារសាមញ្ញៗផ្សេងទៀត ដែលមិនបានផ្ដល់នូវជំនាញសម្រាប់ការរីកចម្រើនក្នុងវិជ្ជាជីវៈឡើយ។ ទោះយ៉ាងណាក្ដី ៥២% នៃកម្មករបានឆ្លើយប្រាប់ថា មិនចង់ផ្លាស់ប្ដូរការងារទេ ហើយ ៤៤% ប្រាប់ថាមិនទាំងដឹងពីការងារអ្វីផ្សេងដែលខ្លួនឯងអាចធ្វើបានផង។

*តពីទំព័រ ១៧* **កំណែទម្រង់វិមជ្ឈការ...**

*Local Rural Governance*. CDRI Working Paper Series No. 94. Phnom Penh: CDRI.

Hughes, Caroline. 2009. *Dependent Communities: Aid and Politics in Cambodia and East Timor*. Ithaca, NY: Cornell Southeast Asia Program.

Kim Sedara. 2012. "Democracy in Action: Decentralization in Post-Conflict Cambodia." PhD dissertation, University of Gothenburg.

Kim Sedara and Joakim Öjendal. 2009. "Decentralization as a Strategy for State Reconstruction in Cambodia." In *Beyond Democracy in Cambodia:Political Reconstruction in a Post-Conflict Society,* edited by J. Öjendal and M. Lilja, 101-135. Copenhagen: NIAS Press.

Malena, Carmen, and Kristina Chhim. 2009. *Linking Citizens and the State: An Assessment of Civil Society Contributions to Good Governance in Cambodia*. Phnom Penh: World Bank Cambodia Country Office.

Martin, Marie Alexandrine. 1994. *Cambodia: A Shattered Society*. Berkeley: University of California Press.

MOEYS, Ministry of Education, Youth and Sport. 2011. *National Policy on Cambodia Youth Development*. Phnom Penh: MOEYS.

NEC, National Election Committee. 2012. "Report on Registered Voters in 2012." Phnom Penh: NEC.

Öjendal, Joakim, and Kim Sedara. 2006. "'Korob, Kaud, Klach': In Search of Agency in Rural Cambodia." *Journal of Southeast Asia Studies* 37(3): 507-526.

# តាមដានសេដ្ឋកិច្ច-សូចនាករ

## តារាង ១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៧-១៤*

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 135.6 | 92.0 | 615.0 | 530.7 | 725.0 | 531.6 | 2.3 | 57.8 | 133.1 | 738.3 | 28.9 | 27.6 |
| ឧស្សាហកម្ម | 709.1 | 724.9 | 818.5 | 403.7 | 2860.1 | 829.3 | 195.4 | 1928.3 | 119.5 | 1014.1 | 179.0 | 239.3 |
| *កាត់ដេរ* | 170.7 | 142.8 | 90.1 | 122.8 | 393.9 | 497.0 | 109.5 | 76.4 | 65.15 | 73.1 | 109.3 | 172.4 |
| សេវាកម្ម | 1742.5 | 10,003.2 | 4432.0 | 1337.3 | 3425.4 | 916.6 | 21.2 | 106.0 | 5.3 | 8.3 | 219.1 | 114.4 |
| *សណ្ឋាគារ និងទេសចរណ៍* | 1048.3 | 8758.1 | 3980.1 | 1105.1 | 2850.9 | 691.5 | 0.0 | 106.0 | 0.0 | 0.0 | 163.3 | 15.4 |
| សរុប | 2587.2 | 10,570.9 | 5865.5 | 2271.7 | 7010.4 | 2278.0 | 218.9 | 2091.1 | 257.9 | 1760.7 | 426.9 | 302.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | -81.1 | 855.5 | -87.7 | 582.8 | -75.8 | -29.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -32.0 | 308.6 | -44.5 | -61.3 | 209 | -67.5 | -47.5 | 666.0 | -39.9 | 52.2 | 95.1 | -85.5 |

* Including expansion project approvals. Source: Cambodian Investment Board

## តារាង ២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៧-១៤

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 79.1 | 154.7 | 64.3 | 36.2 | 185.5 | 175.2 | 145.2 | 10.3 | 51.6 | 110.2 | 27.1 | 8.8 |
| ផ្ទះល្វែង | 297.2 | 221.6 | 149.6 | 183.8 | 219.6 | 372.1 | 114.1 | 33.0 | 62.7 | 131.9 | 106.5 | 75.2 |
| ផ្សេងៗ | 259.6 | 740.9 | 227.3 | 269.7 | 199.9 | 463.6 | 154.4 | 238.3 | 336.0 | 130.8 | 190.0 | 141.7 |
| សរុប | 635.8 | 1117.0 | 441.2 | 489.8 | 605.0 | 1010.9 | 443.7 | 281.6 | 450.3 | 372.9 | 323.6 | 225.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | 590.9 | -36.5 | 59.9 | -17.2 | -13.2 | -30.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 96.7 | 75.7 | -60.5 | 11.0 | 23.5 | 67.1 | 28.1 | -15.6 | 157.5 | 107.6 | -21.8 | -19.8 |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង ៣. ចំនួនភ្ញៀវបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៧-១៤

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ចំនួនភ្ញៀវ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1280.2 | 1239.4 | 1111.7 | 1304.3 | 1480.4 | 1722.1 | 611.2 | 398.1 | 428.0 | 580.4 | 699.0 | 438.2 |
| តាមផ្លូវគោក និងទឹក | 740.5 | 881.9 | 999.7 | 1094.6 | 1401.4 | 1862.2 | 560.9 | 522.5 | 536.6 | 572.5 | 569.0 | 495.2 |
| សរុប | 2020.7 | 2121.3 | 2111.5 | 2398.9 | 2881.8 | 3584.3 | 1172.1 | 920.5 | 964.6 | 1153.0 | 1268.0 | 933.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | 16.4 | -21.5 | 4.8 | 19.5 | 10.0 | -26.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 18.9 | 5.3 | 0.5 | 13.6 | 20.1 | 24.4 | 17.8 | 20.9 | 17.5 | 14.5 | 8.0 | 1.4 |

Source: Ministry of Tourism

## តារាង ៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៧-១៤*

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 3050.3 | 3097.8 | 2901.6 | 3630.2 | 4929.5 | 6106.4 | 1576.9 | 1620.1 | 1969.9 | 1815.4 | 1976.5 | 1859.8 |
| ក្នុងនេះ៖ សម្លៀកបំពាក់ | 2938.9 | 2986.2 | 2565.3 | 3223.4 | 4259.6 | 5015.4 | 1225.2 | 1259.0 | 1568.5 | 1333.4 | 1464.0 | 1379.2 |
| - *ទៅសហរដ្ឋអាមេរិក* | 1956.5 | 1908.3 | 1512.6 | 1853.9 | 2055.3 | 2143.3 | 526.8 | 474.6 | 597.9 | 476.0 | 531.1 | 452.5 |
| - *ទៅសហភាពអឺរ៉ុប* | 654.3 | 689.0 | 644.7 | 809.5 | 1322.2 | 1716.9 | 397.5 | 477.5 | 572.8 | 521.9 | 532.7 | 558.5 |
| - *ទៅអាស៊ាន* | 3.2 | 10.76 | 6.9 | 9.9 | 17.6 | 39.4 | 13.0 | 12.7 | 17.4 | 17.2 | 21.9 | 19.3 |
| - *ទៅជប៉ុន* | 28.5 | 25.2 | 44.5 | 86.5 | 147.0 | 188.6 | 57.6 | 51.4 | 98.1 | 71.6 | 101.4 | 74.9 |
| - *ទៅប្រទេសផ្សេងៗ* | 296.4 | 352.9 | 356.5 | 463.6 | 717.5 | 927.2 | 230.3 | 242.8 | 282.4 | 247.4 | 277.0 | 273.9 |
| កសិកម្ម | 55.7 | 44.5 | 73.1 | 164.9 | 362.1 | 376.7 | 123.8 | 128.9 | 362.4 | 173.0 | 167.0 | 157.3 |
| - *កៅស៊ូ* | 41.0 | 35.8 | 51.6 | 89.1 | 197.6 | 176.6 | 36.6 | 38.7 | 282.4 | 51.1 | 31.7 | 40.0 |
| - *ឈើ* | 8.7 | 3.4 | 3.5 | 34.1 | 48.8 | 36.8 | 14.5 | 8.9 | 16.9 | 33.3 | 55.9 | 48.4 |
| - *ត្រី* | 3.2 | 2.3 | 3.9 | 2.8 | 3.1 | 2.0 | 0.3 | 0.5 | 0.2 | 0.2 | 0.3 | 0.2 |
| - *អង្ករ* | 1.5 | 2.6 | 10.9 | 34.7 | 106.6 | 146.4 | 65.8 | 56.5 | 57.3 | 82.7 | 57.9 | 52.8 |
| - *ផលិតផលកសិកម្មផ្សេងៗ* | 1.2 | 0.5 | 3.0 | 4.1 | 6.0 | 14.9 | 6.6 | 24.4 | 5.7 | 5.7 | 21.2 | 16.0 |
| ផ្សេងៗ | 55.8 | 67.1 | 263.2 | 242.0 | 307.9 | 714.4 | 274.9 | 232.2 | 272.6 | 308.5 | 345.5 | 323.3 |
| ការនាំចូលសរុប | 3770 | 4272.5 | 4331.5 | 5190.6 | 6375.9 | 8593.3 | 2192.1 | 2211.4 | 2059.7 | 2130.1 | 2238.2 | 2449.3 |
| ក្នុងនេះ៖ | | | | | | | | | | | | |
| សាំង | 73.65 | 84.8 | 91.13 | 108.6 | 294.4 | 308.0 | 1225.2 | 77.2 | 71.3 | 80.5 | 77.4 | 83.2 |
| ម៉ាស៊ូត | 133.7 | 19.5 | 180.7 | 203.8 | 447.0 | 559.5 | 526.8 | 137.4 | 150.9 | 132.2 | 148.5 | 142.5 |
| សម្ភារសំណង់ | 44.31 | 56.3 | 49.7 | 57.6 | 48.1 | 66.1 | 397.5 | 17.8 | 18.0 | 17.2 | 27.8 | 29.2 |
| ផ្សេងៗ | 3519.0 | 4011.8 | 4010.0 | 4820.6 | 5586.4 | 7659.1 | 13.0 | 1979.0 | 1819.4 | 1899.6 | 1984.5 | 2194.5 |
| ជញ្ជីងពាណិជ្ជកម្ម | -719.9 | -1174.7 | -1429.9 | -1560.5 | -1446.4 | -1341.6 | -615.2 | -591.2 | -89.8 | -314.7 | -261.7 | -334.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | - | 7.4 | 2.8 | 24.6 | -15.0 | 9.8 | -5.8 |
| ការនាំចេញសរុប | - | - | - | - | - | - | 8.4 | 2.7 | 21.6 | -7.8 | 8.9 | -5.9 |
| ការនាំចូលសរុប | - | - | - | - | - | - | 13.1 | 0.9 | -6.9 | 3.4 | 5.1 | 9.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 8.9 | 1.6 | -14.1 | 25.7 | 32.1 | 17.7 | 14.4 | -14.6 | 18.0 | 16.9 | 19.5 | 9.6 |
| ការនាំចេញសរុប | 8.5 | 1.6 | -6.3 | 25.1 | 35.8 | 23.9 | 23.2 | -8.8 | 23.4 | 24.8 | 25.3 | 14.8 |
| ការនាំចូលសរុប | 23.7 | 13.3 | 1.4 | 19.8 | 22.8 | 16.8 | 36.2 | 17.3 | 2.2 | 9.9 | 2.1 | 10.8 |

* Import data include tax-exempt imports. Sources: Department of Trade Preference Systems, MOC and Customs and Excise Department, MEF (website)

## តារាង ៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៦-១៤ (ពាន់លានរៀល)

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ចំណូលសរុប | 3259.2 | 1146.1 | 5290.0 | 4885.2 | 5989.0 | 6251.4 | 7691.9 | 1820.2 | 2204.8 | 1868.9 | 2361.2 | 2220.5 |
| ចំណូលចរន្ត | 2881.8 | 1141.6 | 5210.7 | 4855.9 | 5859.1 | 6179.3 | 7443.8 | 1817.4 | 2241.3 | 1858.1 | 2316.3 | 2219.2 |
| ចំណូលពន្ធ | 2270.9 | 965.2 | 4409.9 | 4268.0 | 4693.0 | 5277.5 | 6334.8 | 1577.7 | 2024.0 | 1646.0 | 1950.4 | 1988.7 |
| ពន្ធក្នុងស្រុក | - | 661.8 | 3248.4 | 3088.6 | 3533.6 | 4071.6 | 5002.8 | 1254.5 | 1652.9 | 1300.6 | 1520.1 | 1593.6 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | 303.5 | 1161.5 | 1064.7 | 1159.4 | 1205.9 | 1331.7 | 323.1 | 371.1 | 345.4 | 430.3 | 449.0 |
| ចំណូលមិនមែនពន្ធ | 610.9 | 176.4 | 800.8 | 702.1 | 1166.1 | 901.8 | 1118.2 | 239.8 | 217.4 | 212.2 | 365.9 | 176.6 |
| ចំណូលលើទ្រព្យសម្បត្តិ | - | 13.6 | 78.0 | 64.6 | 291.1 | 63.8 | 143.0 | 8.4 | 18.1 | 24.3 | 33.2 | 11.1 |
| លក់ទំនិញ និងសេវា | - | 124.3 | 424.7 | 408.0 | 460.1 | 588.7 | 667.4 | 153.3 | 173.3 | 178.8 | 245.0 | 160.3 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | 38.5 | 298.2 | 228.2 | 408.9 | 249.3 | 298.8 | 78.1 | 25.9 | 9.0 | 87.7 | 5.2 |
| ចំណូលជាមូលធន | 377.4 | 4.5 | 79.3 | 29.3 | 129.9 | 72.1 | 247.9 | 6.2 | 11.5 | 10.7 | 45.0 | 1.3 |
| ចំណាយសរុប | 4174.7 | 1689.7 | 6297.8 | 7383.5 | 8784.6 | 9032.4 | 9660.9 | 2114.8 | 3181.6 | 3093.0 | 4146.4 | 1642.4 |
| ចំណាយជាមូលធន | 1638.1 | 807.4 | 2574.4 | 2694.9 | 2853.2 | 3546.9 | 3628.3 | 1108.4 | 1273.7 | 1350.6 | 1834.8 | 208.5 |
| ចំណាយចរន្ត | 2536.8 | 882.3 | 3809.0 | 4440.0 | 4773.1 | 5341.2 | 6188.4 | 1006.4 | 1907.8 | 1742.4 | 2311.6 | 1433.8 |
| បៀវត្សរ៍ | 822.0 | 362.6 | 1397.0 | 2012.0 | 2048.8 | 2170.6 | 2486.6 | 505.0 | 757.0 | 827.3 | 908.0 | 859.6 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | 194.2 | 927.1 | 871.4 | 1099.4 | 1518.8 | 1586.8 | 252.0 | 652.5 | 285.0 | 373.4 | 213.1 |
| ចំណាយចរន្តផ្សេងទៀត | - | 325.5 | 1384.9 | 1556.6 | 1624.8 | 1651.8 | 2115.1 | 249.4 | 498.3 | 630.1 | 1030.2 | 361.1 |
| សមតុល្យសរុប | -915.5 | -543.6 | -1007.8 | -2498.3 | -2795.7 | -1271.4 | -1969.0 | -294.6 | -976.7 | -1224.1 | -1785.2 | 578.1 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | -445.1 | 741.5 | 2055.10 | 1746.1 | 1845.2 | -2781.0 | 2457.8 | 906.0 | 1150.6 | 1032.2 | 1237.4 | -14.4 |
| ហិរញ្ញប្បទានក្នុងស្រុក | - | -185.8 | -127.00 | 474.9 | 938.6 | 2379.2 | -332.9 | -470.6 | 270.3 | 113.0 | 65.8 | -14.4 |

Source: MEF website

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៧-១៤

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 5.8 | 19.7 | -0.7 | 4.1 | 5.4 | 2.3 | 1.5 | 2.3 | 3.7 | 4.7 | 4.6 | 4.8 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 9.9 | 33.1 | -0.3 | 4.4 | 6.5 | 2.5 | 1.6 | 3.3 | 4.8 | 5.8 | 5.7 | 5.3 |
| - ដឹកជញ្ជូន | 5.8 | 19.4 | -10.7 | 7.0 | 6.9 | 3.3 | -0.7 | -1.0 | -0.1 | -0.4 | -1.1 | 0.5 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4062.7 | 4058.2 | 4140.5 | 4187.1 | 4063.6 | 4039.2 | 3995 | 4033.1 | 4062.0 | 4059.0 | 3993.8 | 4026.9 |
| រៀលក្នុង ១ បាតថៃ | 122.8 | 123.5 | 121.1 | 133.1 | 133.2 | 130.0 | 134.7 | 135.74 | 131.4 | 130.7 | 123.0 | 124.8 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.0 | 24.8 | 23.4 | 21.7 | 19.7 | 19.4 | 19.3 | 19.3 | 19.3 | 19.4 | 19.1 | 19.2 |
| ថ្លៃមាស (ដុល្លារ/ជី) | 83.2 | 105.9 | 113.1 | 147.5 | 184.5 | 200.9 | 197.3 | 173.4 | 161.1 | 171.8 | 156.6 | 155.9 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 3262.3 | 4555.2 | 3170.9 | 3859.3 | 4761.2 | 4941.2 | 5134.4 | 4992.0 | 5022.5 | 4927.0 | 4971.2 | 5006.7 |
| ថ្លៃសាំង (រៀល/លីត្រ) | 4005.0 | 4750.8 | 3593.1 | 4368.1 | 5044.5 | 5312.7 | 5410.5 | 5274.5 | 5245.2 | 5126.7 | 5171.5 | 5200.0 |

Sources: NIS, NBC and CDRI

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៧-១៤ (តួលេខនៅចុងការិយបរិច្ឆទ)

| | 2007 | 2009 | 2009 | 2010 | 2011 | 2012 | 2013 | | | | 2014 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 10,735.0 | 10,345.0 | 14,655.0 | 16,697.9 | 17,893.9 | 18,154.5 | 19,976.7 | 21,772.9 | 18,720.7 | 21,260.1 | 23,344.4 | 26,235.8 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 576.0 | 1513.3 | 1573.0 | 2778.9 | 5760.8 | 10,437.4 | 10,504.1 | 9886.1 | 10,634.8 | 11,508.3 | 11,817.4 | 12,024.4 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -1816.0 | -2987.0 | -2252.0 | -2126.6 | -2123.1 | -2486.4 | -2991.6 | -3012.6 | -2804.4 | -2794.9 | -3349.3 | -3747.3 |
| ឥណទានដល់ផ្នែកឯកជន | 6386.0 | 9894.0 | 10,532.0 | 13,331.2 | 17,552.8 | 23,536.6 | 24,820.2 | 25,146.0 | 26,445.3 | 27,608.8 | 28,584.5 | 30,621.3 |
| រូបិយវត្ថុទូទៅ M2 | 11,311.0 | 11,858.0 | 16,228.0 | 19,476.8 | 23,654.7 | 28,591.9 | 30,480.8 | 31,659.1 | 29,355.5 | 32,768.4 | 35,161.8 | 38,259.9 |
| រូបិយវត្ថុ M1 | 2052.0 | 2399.0 | 3120.0 | 3220.9 | 3956.2 | 4045.7 | 4500.6 | 4585.9 | 4720.8 | 4878.2 | 5376.2 | 5231.3 |
| រូបិយវត្ថុផ្សេងៗ | 9259.0 | 9459.0 | 13,108.0 | 16,255.9 | 19,698.5 | 24,546.2 | 25,980.2 | 27,073.2 | 24,634.8 | 27,890.2 | 29,785.7 | 33,028.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 62.9 | 4.8 | 36.9 | 20.0 | 17.8 | 20.9 | 22.6 | 18.8 | 9.3 | 14.6 | 15.4 | 20.8 |
| រូបិយវត្ថុ M1 | 23.8 | 16.9 | 30.1 | 3.2 | 16.9 | 2.3 | 12.9 | 18.4 | 23.6 | 20.6 | 19.5 | 14.1 |
| រូបិយវត្ថុផ្សេងៗ | 75.2 | 2.2 | 38.6 | 24.0 | 17.9 | 44.6 | 24.4 | 18.8 | 6.9 | 13.6 | 14.6 | 22.0 |

Source: National Bank of Cambodia

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2011 | 2012 | 2013 | | | | 2014 | | | 2014 | | |
| | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆកា | កុម្ភៈ | ឧសភា | សីហា | កុម្ភៈ | ឧសភា | សីហា |
| អ្នកធាក់ស៊ីក្លូ | 9532 | 10,303 | 9592 | 10,681 | 10,636 | 10,842 | 10,832 | 10,764 | 9867 | 12.9 | 0.8 | -7.2 |
| អ្នកលីសែង | 10,785 | 12,143 | 12,749 | 12,823 | 14,157 | 13,260 | 12,141 | 12,568 | 13,399 | -4.8 | -2.0 | -5.4 |
| អ្នកលក់បន្លែតូចតាច | 8337 | 10,771 | 9953 | 11,571 | 11,490 | 12,449 | 12,294 | 13,581 | 15,372 | 23.5 | 17.4 | 33.8 |
| អ្នករើសអេតចាយ | 8388 | 8680 | 9487 | 10,440 | 9620 | 9732 | 9593 | 9214 | 8337 | 1.1 | -11.7 | -13.3 |
| អ្នកបម្រើភោជនីយដ្ឋាន* | 5986 | 6111 | 6529 | 6744 | 6791 | 6723 | 7449 | 6696 | 7565 | 14.1 | -0.7 | 11.4 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5695 | 6151 | 5811 | 6427 | 7771 | 6388 | 8932 | 5836 | 8795 | 53.7 | -9.2 | 13.2 |
| កម្មកររោងចក្រកាត់ដេរ | 8409 | 8932 | 10,004 | 9776 | 10,420 | 10,442 | 9548 | 11,412 | 11,388 | -4.6 | 16.7 | 9.3 |
| អ្នករត់ម៉ូតូឌុប | 11,568 | 12,930 | 14,433 | 12,522 | 13,656 | 13,189 | 13,227 | 13,401 | 12,656 | -8.4 | 7.0 | -7.3 |
| កម្មករសំណង់គ្មានជំនាញ | 10,307 | 11,078 | 12,554 | 13,728 | 13,023 | 13,431 | 15,162 | 15,316 | 15,401 | 20.8 | 11.6 | 18.3 |
| កម្មករសំណង់មានជំនាញ | 13,159 | 13,743 | 15,162 | 14,136 | 15,822 | 16,647 | 15,163 | 15,765 | 20,420 | 0.0 | 11.5 | 29.1 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the incomes of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI